ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៥០..សសរ

# សេចក្តីសំរេច
## ស្តីពី
## ការកែសម្រួលសមាសភាពការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង
## ប្រចាំនៅក្រុងព្រះសីហនុ

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-យោងសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុងប្រចាំនៅក្រុងព្រះសីហនុ ។

-យោងតាមលិខិតលេខ ០៥៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាក្រុងព្រះសីហនុ

## សំរេច

**ប្រការ១** : ត្រូវបានកែសម្រួល តែងតាំងប្រធាន និងអនុប្រធានការិយាល័យសន្តិសុខថ្នាក់ក្រុង ប្រចាំនៅក្រុងព្រះសីហនុ មានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១-ឯក ឧត្តម | **ឈុន ស៊ីរុន** | អភិបាលរងទី ១ ក្រុង | **ប្រធាន** |
| ២-ឯក ឧត្តម | **ទ្រាក់ ស៊ីមហាវ៉ា** | អភិបាលរងទី ២ ក្រុង | **អនុប្រធាន** |

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួង-ការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការ-ដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថ-លើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល
-ដូចប្រការ២
-សាលាក្រុងព្រះសីហនុ
-ឯកសារ-កាលប្បវត្តិ